# មេរៀនទី ១៦: ព្រះយេស៊ូវលាងជើងឲ្យពួកសិស្ស

## យ៉ូហាន ១៣:១-១៧

**គោលបំណង៖** ព្រះយេស៊ូវចង់ឲ្យយើងបំរើអ្នកដទៃ។

**ខគម្ពីរចងចាំ៖** ១ ពេត្រុស ៤:១០ក *"គឺដោយខំបំរើគ្នាទៅវិញទៅមក តាមអំណោយទានដែលគ្រប់គ្នាបានទទួលមកទុកដូចជាអ្នកចែកចាយយ៉ាងល្អ.... ។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ពន្ធកិច្ចទាំងមូលរបស់ព្រះយេស៊ូវគឺជាការបន្ទាបខ្លួន។ ស្រមៃថាស្តេចមួយអង្គចាកចេញពីវាំងទៅរស់នៅជាបុរសអនាថាក្រីក្រ។ តើមានអ្នកណានឹងធ្វើបែបនេះបានដែរឬទេ? ទេ! ប៉ុន្តែ ព្រះយេស៊ូវបានចាកចេញពីនគររបស់ទ្រង់នៅស្ថានសួគ៌ ហើយមកផែនដីនេះដោយសារទ្រង់ស្រឡាញ់អ្នក។ សូមអរព្រះគុណព្រះយេស៊ូវដែលបានសង្គ្រោះយើង ដើម្បីឲ្យយើងអាចរស់នៅក្នុងនគររបស់ព្រះអង្គនៅថ្ងៃណាមួយ។ ដោយសារយើងមានព្រះយេស៊ូវ យើងមិនត្រូវខ្មាស់ក្នុងការជួបព្រះឡើយ។ ទ្រង់បានបន្ទាបខ្លួនចុះដល់ចំណុចមួយដែលទ្រង់សុគតលើឈើឆ្កាងសម្រាប់យើង ដូច្នេះទ្រង់លើកយើងឡើងឲ្យខ្ពស់ហើយចូលទៅក្នុងនគររបស់ទ្រង់។ នៅពេលអ្នកបង្រៀនមេរៀននេះ សូមបង្ហាញស្មារតីនៃការបន្ទាបខ្លួនទៅចំពោះកូនសិស្សរបស់អ្នក ។

**ចំរៀង៖** ១. ចូរសរសើរព្រះយេស៊ូវ ២. គឺជាការល្អដែលសរសើរព្រះ ៣. ចូរបន្ទាបខ្លួននៅចំពោះព្រះអង្គ

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត «អ្នកបម្រើ ឬក៏ចៅហ្វាយនាយ»**

**ជម្រើសទី១៖ អ្នកបម្រើ ឬក៏ចៅហ្វាយនាយ**

**សម្ភារៈដែលត្រូវការ៖** ក្រដាសជាមួយនឹងសញ្ញា "O" ឬ "X" សម្រាប់ឲ្យកុមារគ្រប់ៗគ្នា

១. ពេលដែលកុមារដើរចូលមក សូមឲ្យក្រដាសដែលបានរៀបចំហើយ ដែលមានសញ្ញា "O" ឬ "X" ទៅពួកគេ

២. សូមពន្យល់កុមារដែលកាន់ក្រដាស "O" គឺជាអ្នកបំរើ ហើយកុមារដែលកាន់ក្រដាស "X" ជាចៅហ្វាយនាយ

៣. សូមឲ្យកុមារដែលជាចៅហ្វាយប្រាប់ទៅអ្នកបំរើពីអ្វីដែលពួកគេត្រូវធ្វើ(សំអាតព្រះវិហារ យកទឹកឲ្យ កាន់កាបូបឲ្យ ។ល។)

៤. ប្រាំនាទីក្រោយមក សូមផ្លាស់ប្តូរតួនាទីរបស់កុមារ ដែលកាន់ក្រដាសអក្សរ "O" ជាចៅហ្វាយនាយ ហើយកុមារដែលកាន់ក្រដាសអក្សរ "X" ជាអ្នកបំរើវិញ។

**ជម្រើសទី២៖ ស្តេច ម្ចាស់ក្សត្រី មេទ័ព**

**របៀបលេង៖**ឲ្យកុមារចាប់ដៃគូ ២ៗនាក់ ម្នាក់ជាអ្នកបម្រើ ម្នាក់ទៀតជាស្តេច ម្ចាស់ក្សត្រី មេទ័ព (ឲ្យកុមារចូលរួមលេងល្បែងនេះទាំងអស់គ្នា)

**ពន្យល់ពីកាយវិការ៖** "ស្តេច" ដាក់ជង្គង់ម្ខាងលើខ្នងដៃគូដែលអង្គុយលត់ជង្គង់នោះ "ម្ចាស់ក្សត្រី" អង្គុយលើ

ចង្អុះដៃគូរនោះ "មេទ័ព" អៀវគ្នា។

**បញ្ជាក់:**សូមឲ្យកុមារធ្វើកាយវិការឲ្យលឿនតាមគ្រូស្រែក(ស្ដេច ម្ចាស់ក្សត្រី មេទ័ព)បើគ្រូនិយាយថា "ស្ដេច" កុមារដែលជាស្ដេចត្រូវធ្វើកាយវិការស្ដេច អ្នកបម្រើត្រូវអង្គុយលុតជង្គង់និងច្រត់ដៃទាំងពីរលើឥដ្ឋ បើគ្រូស្រែកថាដូរ កុមារត្រូវដូរតួនាទីគ្នាធ្វើ។ ឧទាហរណ៍៖ ស្ដេចត្រូវធ្វើជាអ្នកបម្រើវិញម្ដង។បើគូរណាធ្វើខុស គូរនោះជាអ្នកចាញ់។

## ៤. ការណែនាំមេរៀន

យើងទើបតែលេងល្បែងដែលយើងបានធ្វើជាអ្នកបំរើផង និងចៅហ្វាយនាយផង។ បើសិនអាចជ្រើសរើសបាន តើអ្នកនឹងចង់ធ្វើជាអ្វី? ជាអ្នកបំរើ ឬជាចៅហ្វាយនាយ? ខ្ញុំគិតថាយើងនឹងរើសយកធ្វើជាចៅហ្វាយនាយ។

សូមសួរកុមារថា ស្រមៃមើលបើសិនអ្នកជាស្ដេច ឬម្ចាស់ក្សត្រីនៃប្រទេសមួយ តើមានអ្វីខ្លះដែលអ្នកចង់ធ្វើក្នុងនាមអ្នកជាស្ដេច ឬម្ចាស់ក្សត្រីនោះ? ត្រូវហើយ មានរឿងជាច្រើនដែលអ្នកអាចធ្វើបាន ប្រសិនបើអ្នកជាស្ដេច ឬក៏ម្ចាស់ក្សត្រី។ អ្នកអាចរស់នៅក្នុងព្រះបរមរាជវាំង។ អ្នកអាចញ៉ាំអ្វីដែលអ្នកចង់ញ៉ាំក៏បាន ហើយធ្វើអ្វីដែលអ្នកចង់ធ្វើក៏បាន។ អ្នកអាចស្លៀកសំលៀកបំពាក់ថ្លៃៗ និងអ្នកអាចទទួលបាននូវប្រដាប់ក្មេងលេង និងឧបករណ៍ហ្គេមជាច្រើនដែលអ្នកចង់បាន។ តើអ្នកនឹងបោះបង់ចោលតំណែងជាស្ដេច ឬម្ចាស់ក្សត្រីទៅធ្វើជាជនក្រីក្រដែរឬទេ?

យើងទាំងអស់គ្នាដឹងថា នរណាជាអ្នកបោះបង់បល្ល័ង្ករបស់ទ្រង់ដើម្បីសង្គ្រោះយើងគ្រប់គ្នា។ តើម្នាក់នោះជានរណា? ព្រះយេស៊ូវ! ព្រះយេស៊ូវបានចាកចេញពីនគរឋានសួគ៌ ហើយបានមករស់នៅជាបុរសក្រីក្រម្នាក់ ហេតុអ្វីបានជាព្រះអង្គធ្វើដូច្នេះ? ទ្រង់ធ្វើបែបនេះពីព្រោះព្រះអង្គស្រឡាញ់យើងរាល់គ្នា។ ទ្រង់បានមករកយើងរាល់គ្នាដូចជាអ្នកបំរើដែលស្លូតបូត តែមិនមែនជាចៅហ្វាយដ៏កាចសាហាវនោះទេ។ សូមរៀនពីសាច់រឿងដែលបង្ហាញពីការបំរើដ៏រាបទាបនិងស្លូតបូតរបស់ទ្រង់។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ព្រះគម្ពីរបានប្រាប់យើងពីពេលវេលាដែលព្រះយេស៊ូវបានបំរើដល់សិស្សរបស់ទ្រង់ដោយរាបទាប។ នៅក្នុងពេលនោះដោយផ្អែកទៅតាមព្រះគម្ពីរ នៅពេលមាននរណាម្នាក់មកផ្ទះរបស់អ្នក អ្នកបំរើនឹងលាងជើងឲ្យភ្ញៀវ ពីព្រោះផ្លូវនៅជំនាន់នោះពោរពេញដោយធូលីដី។ ពេលដែលព្រះយេស៊ូវ និងពួកសិស្សមកជួបជុំគ្នា ដើម្បីបរិភោគអាហារដ៏ពិសេសដែលហៅថាបុណ្យរំលង គ្រប់គ្នាត្រូវតែលាងជើងជាមុនសិន។ ប៉ុន្តែមិនមានអ្នកបំរើណាមកលាងជើងឲ្យព្រះយេស៊ូវ និងពួកសិស្សនោះទេ។ ព្រះយេស៊ូវអាចប្រាប់សិស្សរបស់ទ្រង់ណាម្នាក់ ឲ្យមកលាងជើងឲ្យទ្រង់ ឬឲ្យទៅរកអ្នកបំរើណាម្នាក់មកលាងជើងឲ្យទ្រង់ក៏បាន។

ប៉ុន្តែព្រះយេស៊ូវបានធ្វើឲ្យសិស្សរបស់ទ្រង់មានការភ្ញាក់ផ្អើល ដោយទ្រង់បានយកកន្សែងមករុំលើសម្លៀកបំពាក់របស់ទ្រង់ ហើយចាប់ផ្ដើមលាងជើងឲ្យសិស្សរបស់ទ្រង់ម្នាក់ម្ដងៗ។ ព្រះយេស៊ូវបានធ្វើអ្វីដែលការងាររបស់អ្នកបំ-រើត្រូវធ្វើ! ពេលដែលព្រះយេស៊ូវទៅដល់មុខពេត្រុស ពេត្រុសបាននិយាយថា "អូ! អត់ទេព្រះយេស៊ូវ ទូលបង្គំមិនចង់ឲ្យទ្រង់លាងជើងឲ្យទូលបង្គំទេ" ពេត្រុសដឹងថាព្រះយេស៊ូវជាអ្នកដែលអស្ចារ្យបំផុតក្នុងចំណោមពួកគេទាំងអស់ ហើយមិនគួរឲ្យទ្រង់មកធ្វើការងារជាអ្នកបំរើឡើយ។ ប៉ុន្តែព្រះយេស៊ូវមានបន្ទូលថា នេះជារឿងសំខាន់សំរាប់ទ្រង់។

បន្ទាប់មកព្រះយេស៊ូវបានសួរទៅសិស្សរបស់ទ្រង់ “តើអ្នកយល់ពីអ្វីដែលខ្ញុំបានធ្វើទេ?” ព្រះអង្គបានប្រាប់ ពួកគេថា “ខ្ញុំធ្វើនេះដើម្បីបង្ហាញជាគំរូសំរាប់អ្នកឲ្យធ្វើតាមខ្ញុំ។ អ្នកត្រូវតែក្លាយទៅជាអ្នកបំរើ” នៅពេលដែលព្រះយេស៊ូវលាងជើងឲ្យពួកសិស្ស ទ្រង់បានបង្រៀនពួកគេថាទ្រង់យាងមកបំរើមនុស្ស ហើយទ្រង់ចង់ឲ្យពួកគេបំរើគ្នាទៅវិញទៅមក។ ថ្ងៃនេះព្រះយេស៊ូវកំពុងមានបន្ទូលប្រាប់យើងទាំងអស់គ្នាឱ្យមានបេះដូងជាអ្នកបម្រើ ហើយមានឆន្ទៈក្នុងការបំរើមនុស្សក្នុងជីវិតរបស់អ្នក ដូចជាឪពុកម្តាយ បងប្អូន មិត្តភក្តិ គ្រូបង្រៀន និងអ្នកដទៃជាច្រើនទៀត។ តើអ្នកគិតថាអ្នកអាចមានចិត្តបំរើដូចព្រះយេស៊ូវដែរឬទេ?

**៦. សំនួរពិភាក្សា**

១.តាមរយៈសាច់រឿងនេះ តើអ្នកបំរើត្រូវធ្វើអ្វីខ្លះពេលដែលមានភ្ញៀវមកលេងផ្ទះពួកគេ? *លាងជើងឲ្យភ្ញៀវ*

២.តើព្រះយេស៊ូវធ្វើអ្វីខ្លះនៅពេលគ្មានអ្នកបំរើមកលាងជើងឲ្យពួកគេ?
*ព្រះយេស៊ូវបានលាងជើងឲ្យសិស្សរបស់ទ្រង់*

៣. តើព្រះយេស៊ូវព្យាយាមបង្ហាញអ្វីដល់សិស្សរបស់ទ្រង់ដោយទ្រង់បានលាងជើងដូចជាអ្នកបំរើ?
*ពួកសិស្សត្រូវមានចិត្តជាអ្នកបំរើ*

៤. តើអ្នកអាចបំរើអ្នកដទៃនៅក្នុងជីវិតរបស់អ្នកដោយរបៀបណា?*លាងចាន ជួយបងប្អូនបង្កើតជួយមិត្តភក្តិ*

**៧. ខគម្ពីរចងចាំ** ១ ពេត្រុស ៤:១០ក

**៨. ហត្ថកម្ម** «អរគុណគ្រូគង្វាល!»

**សម្ភារៈដែលត្រូវការៈ** ឈើដោតការ៉េម ក្រដាស់ពណ៌ កន្ត្រៃ ជ័រការ ប៊ិច



១. វិធីមួយនៃការបំរើនោះគឺការអរគុណដល់មនុស្សដែលបានបម្រើអ្នក។ ហើយម្នាក់ដែលបំរើយើងដោយចេញពីចិត្តនោះគឺគ្រូគង្វាល។ ថ្ងៃនេះយើងនឹងធ្វើជាផ្កាហើយបិតនៅលើដងការ៉េមកីដើម្បីជូនដល់គ្រូគង្វាលរបស់យើង។

២. ឲ្យក្រដាសពណ៌ទៅកុមារគ្រប់គ្នាសំរាប់កុមារតូចៗ ពួកគេអាចយកបាតដៃរបស់ពួកគេដាក់លើក្រដាស គូសតាមគម្រូដៃរបស់គេ រួចកាត់តាមដានដៃនោះ បន្ទាប់មកយកវាមកបិតនៅលើដងការ៉េម។ សំរាប់ក្មេងធំៗពួកគេអាចកាត់ជារូបផ្កា ហើយបិតវានៅលើដងការ៉េម។



៣. ពេលដែលក្មេងៗជូនផ្កាទៅគ្រូគង្វាល ពួកគេអាចប្រាប់គ្រូគង្វាលថា “អរគុណលោកគ្រូ/ អ្នកគ្រូដែល បានធ្វើជាគ្រូគង្វាលរបស់យើង”

៤. បើសិនអ្នកមានពេលវេលាថែមទៀត ពួកគេគួរតែធ្វើផ្កាទាំងនោះសំរាប់ជាការអរគុណដល់ឪពុកម្តាយរបស់ពួកគេផងដែរ។

**៩. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១០. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*